សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

Cambodian Journalists Alliance Association

# របាយការណ៍ឃ្លាំមើលប្រចាំត្រីមាសស្តីពី

# ស្ថានភាពសារព័ត៌មាននៅកម្ពុជា




ខែតុលា - ធ្នូ ឆ្នាំ២០២៥ | លេខចេញផ្សាយ ១៨

# សេចក្តីថ្លែងអំណរគុណ

វិធីសាស្រ្តតាមដានដែលបានប្រើប្រាស់ក្នុងរបាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយបានសហការជាមួយអ្នកស្រី Dara Torsner ជាសាស្រ្តាចារ្យ និងជាអ្នកស្រាវជ្រាវអំពីសុវត្ថិភាពអ្នកសារព័ត៌មានមកពីចក្រភពអង់គ្លេស។ យើងសូមថ្លែងអំណរគុណជាខ្លាំងចំពោះអ្នកស្រីសាស្រ្តាចារ្យ ដែលបានផ្តល់នូវការប្រឹក្សាដ៏មានតម្លៃក្នុងការបង្កើតទាំងវិធីសាស្រ្តនិងការរៀបចំរបាយការណ៍នេះ។

# មាតិកា


១. របាយការណ៍សង្ខេប ........ ៤

២. សេចក្តីផ្តើម ........ ៨

៣. វិធីសាស្រ្តឃ្លាំមើលផ្អែកលើសិទ្ធិមនុស្ស ........ ១៣

៤. ការរកឃើញសំខាន់ៗ ........ ១៩

៥. សេចក្តីសន្និដ្ឋាន ........ ២០

៧. ឧបសម្ព័ន្ធ ........ ៣៣

# ១. របាយការណ៍សង្ខេប

របាយការណ៍ឃ្លាំមើលប្រចាំត្រីមាសរបស់ខេមបូចាស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជា គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់ខេមបូចាក្នុងការចងក្រងឯកសារនិងវិភាគស្ថានភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។ របាយការណ៍ទាំងនេះមានគោលបំណងផ្តល់ជូនភាគីពាក់ព័ន្ធនូវព័ត៌មានផ្អែកលើភស្តុតាង ដើម្បីគាំទ្រកិច្ចការ តស៊ូមតិ លើកកម្ពស់ការយល់ដឹង និងជាមូលដ្ឋានសម្រាប់កំណែទម្រង់គោលនយោបាយ ក្នុងការការពារអ្នកសារព័ត៌មាន និងលើកកម្ពស់លំហប្រព័ន្ធផ្សព្វផ្សាយដែលសេរី និងមានសុវត្ថិភាពនៅកម្ពុជា។

ការរកឃើញក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ (ខែតុលា ដល់ខែធ្នូ) បង្ហាញពីបញ្ហាប្រឈមដែល នៅតែបន្តកើតមានឡើងចំពោះសេរីភាពប្រព័ន្ធផ្សព្វផ្សាយ និងសិទ្ធិមនុស្សមូលដ្ឋាននៅក្នុងប្រទេស។ ក្នុងអំឡុងពេលចងក្រងរបាយការណ៍នេះ ខេមបូចា បានកត់ត្រាករណីរំលោភបំពានសិទ្ធិលើអ្នកសារព័ត៌មានចំនួន១៤ករណី ដែលករណីទាំងអស់ពាក់ព័ន្ធនឹងការងារសារព័ត៌មាន។ ករណីដែលបានកត់ត្រាទាំងនោះរួមមាន អំពើហិង្សាលើរាងកាយ ការគំរាមកំហែង ការអនុវត្តវិធានការផ្លូវច្បាប់មិនត្រឹមត្រូវតាមនីតិវិធីច្បាប់ និងការបង្ខាំង ឬឃុំខ្លួនជាដើម។

អ្នកសារព័ត៌មានជាស្ត្រីចំនួន៤នាក់ ត្រូវបានកំណត់ជាគោលដៅនៃការរំលោភបំពាន។ ក្នុងនោះអ្នកសារព័ត៌មានស្ត្រីម្នាក់ បានរងនូវការបំពានផ្លូវភេទដែលរាប់ចូលក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រ ដែលរួមមានទាំងការបំពានលើរាងកាយ និងផ្លូវចិត្ត ក្រោមទម្រង់ជាការបំពានផ្លូវភេទនៅកន្លែងការងារ។ ករណីផ្សេងទៀតរួមមានការគំរាមកំហែងបង្កហិង្សាលើរាងកាយ ការបំភ័យដោយពាក្យសំដីពីប្រភពព័ត៌មាន និងការចាប់ខ្លួនពាក់ព័ន្ធនឹងការរាយការណ៍អំពីជម្លោះព្រំដែនកម្ពុជា-ថៃ។ តួអង្គរដ្ឋជាពិសេសអាជ្ញាធរនៅថ្នាក់មូលដ្ឋានត្រូវបានរាយការណ៍ថាជាអ្នកពាក់ព័ន្ធចម្បងក្នុងការរំលោភបំពានដែលបានកត់ត្រាក្នុងត្រីមាសនេះ។

និន្នាការនេះឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងទូលំទូលាយនៃបញ្ហានិទណ្ឌភាពដែលអំពើរំលោភបំពានប្រឆាំងនឹងអ្នកសារព័ត៌មានប្រព្រឹត្តដោយតួអង្គរដ្ឋជារឿយៗមិនត្រូវបានផ្តន្ទាទោសឡើយ។ វដ្តនៃភាពអយុត្តិធម៌នេះបានធ្វើឱ្យជំនឿចិត្តលើប្រព័ន្ធយុត្តិធម៌ធ្លាក់ចុះ និងបានបើកផ្លូវឱ្យអំពើរំលោភបំពានបន្តកើតមានឡើង ខណៈដែលអ្នកសារព័ត៌មានជាច្រើនជ្រើសរើសមិនរាយការណ៍ការរងអំពើរំលោភបំពានសិទ្ធិប្រឆាំងនឹងពួកគេ ដោយសារតែការភ័យខ្លាចចំពោះការសងសឹក ការខ្វះទំនុកចិត្តលើអាជ្ញាធរ ឬការយល់ឃើញថាគ្មានចំណាត់ការសមស្របណាមួយនឹងត្រូវបានអនុវត្តនោះទេ។

ការរំលោភបំពានសិទ្ធិទាំងនេះដែលបានកត់ត្រាដោយខេមបូចា មិនត្រឹមតែរំលោភលើសិទ្ធិ សេរីភាពសារព័ត៌មានដែលធានាដោយរដ្ឋធម្មនុញ្ញកម្ពុជាប៉ុណ្ណោះទេ ជាពិសេសមាត្រា ៤១ ដែលចែងថាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាពបញ្ចេញមតិ សារព័ត៌មាន ការបោះពុម្ពផ្សាយ និងការប្រជុំ។ ការរំលោភបំពានទាំងនេះក៏ផ្ទុយនឹងស្តង់ដារអន្តរជាតិក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ផងដែរ រួមមានសិទ្ធិមូលដ្ឋានដូចជា សេរីភាពបញ្ចេញមតិ សុវត្ថិភាពលើរាងកាយ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌និងនីតិវិធីត្រឹមត្រូវ ព្រមទាំងសេរីភាពផ្ទាល់ខ្លួនផងដែរ។ ការរំលោភបំពានសិទ្ធិដែលបានកត់ត្រាទាំងនេះបានបង្ហាញអំពី





ផលវិបាកធ្ងន់ធ្ងររបស់អ្នកសារព័ត៌មានម្នាក់ៗ រួមមានការដាក់កម្រិតលើសេរីភាពធ្វើដំណើរ ផលប៉ះពាល់/របួសផ្លូវចិត្ត ការដាក់កំហិតលើខ្លួនឯងក្នុងការរាយការណ៍ព័ត៌មាន និងការបង្ខំឱ្យទទួលស្គាល់កំហុស ឬចុះហត្ថលេខាលើលិខិតសុំទោសជាដើម។

ការរកឃើញទាំងនេះបង្ហាញពីនិន្នាការស្រដៀងនឹងត្រីមាសមុនៗក្នុងឆ្នាំ២០២៥ដែលវិធានការផ្លូវច្បាប់ត្រូវបានប្រើដើម្បីបំភ័យឬបំបិទមាត់អ្នកសារព័ត៌មានដែលរាយការណ៍ពីប្រធានបទរសើបឬបញ្ហាពាក់ព័ន្ធនឹងអាជ្ញាធរ។ និន្នាការនៃការបំភ័យនេះបានបង្កើតបរិយាកាសភ័យខ្លាច ដែលនាំឱ្យមានការដាក់កំហិតលើខ្លួនឯងកាន់តែច្រើនក្នុងចំណោមអ្នកសារព័ត៌មាន និងបង្កផលប៉ះពាល់អវិជ្ជមានលើការពិភាក្សាសាធារណៈ។ បញ្ហានេះបញ្ជាក់ជាថ្មីពីតម្រូវការបន្ទាន់ក្នុងការកែទម្រង់ជាប្រព័ន្ធដើម្បីការពារសេរីភាពសារព័ត៌មាននិងធានាថា កម្ពុជាបំពេញកាតព្វកិច្ចជាតិ និងអន្តរជាតិរបស់ខ្លួនក្រោមច្បាប់សិទ្ធិមនុស្ស។

ការបន្តប្រើប្រាស់ការគំរាមកំហែង និងវិធានការផ្លូវច្បាប់តាមអំពើចិត្ត ដើម្បីបំភិតបំភ័យអ្នកសារព័ត៌មាន និងទប់ស្កាត់ការរាយការណ៍ព័ត៌មានបែបរិះគន់ បង្ហាញពីនិន្នាការគួរឱ្យព្រួយបារម្ភនៃការបំភ័យតាមផ្លូវច្បាប់។

ដូចដែលខេមបូចាបានចងក្រងក្នុងត្រីមាសមុនៗនៃឆ្នាំ២០២៥អាជ្ញាធរកំពុងប្រើប្រាស់បទចោទព្រហ្មទណ្ឌរួមមានបទញុះញង់ប្រឆាំងនឹងអ្នកសារព័ត៌មានដែលរាយការណ៍អំពីប្រធានបទរសើបជំនួសឱ្យការប្រើប្រាស់យន្តការស៊ីវិលដែលមានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាននៅកម្ពុជា។ វិធីសាស្ត្រនេះផ្ទុយនឹងស្តង់ដារអន្តរជាតិ ដែលការពារ សេរីភាពបញ្ចេញមតិ។ ការរឹតត្បិតលើការងារសារព័ត៌មានបែបនេះ រារាំងសាធារណជនពីការទទួលបានព័ត៌មាន និងប៉ះពាល់ដល់ការចូលរួមដែលមានអត្ថន័យក្នុងការពិភាក្សាសាធារណៈ។

ទោះបីមានបញ្ហាប្រឈមកើនឡើងចំពោះសារព័ត៌មានសេរីនិងឯករាជ្យនៅកម្ពុជាក៏ដោយ ខេមបូចានៅតែបន្តប្តេជ្ញាផលិត និងលើកកម្ពស់ការរាយការណ៍ព័ត៌មានដែលផ្អែកលើការពិត និងមិនលំអៀង។ យើងជឿជាក់ថា ការលើកឡើងអំពីបញ្ហាប្រឈមដែលធ្វើឱ្យការងាររបស់អ្នកសារព័ត៌មានកាន់តែលំបាក គឺមានសារៈសំខាន់ណាស់។ ខេមបូចា សង្ឃឹមថានឹងជួយលើកស្ទួយបរិយាកាសដែលស្របតាមការធានាសិទ្ធិសេរីភាពបញ្ចេញមតិ និងនិយាយស្តីដែល មានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ដើម្បីឱ្យអ្នកសារព័ត៌មានទាំងអស់អាចបំពេញការងាររបស់ខ្លួនបានដោយមិនមានការភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពរបស់អ្នកនៅជុំវិញខ្លួន។

របាយការណ៍ឃ្លាំមើលប្រចាំត្រីមាស

# ២. សេចក្តីផ្តើម

ការឃ្លាំមើលរបស់ខេមបូចា បង្ហាញថាបរិយាកាសសម្រាប់សារព័ត៌មានឯករាជ្យនៅកម្ពុជានៅតែបន្តធ្លាក់ចុះ។ ការរឹតត្បិតកាន់តែកើនមានឡើង បន្ទាប់ពីក្រសួងព័ត៌មានបានណែនាំបទប្បញ្ញត្តិថ្មីៗសម្រាប់ប្រព័ន្ធផ្សព្វផ្សាយដែលមានគោលបំណងគ្រប់គ្រងការងារសារព័ត៌មាន។ ចន្លោះខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៥ ខេមបូចាបានសង្កេតឃើញនិន្នាការគួរឱ្យព្រួយបារម្ភចំពោះសេរីភាពសារព័ត៌មាន ទាក់ទងនឹងប្រកាសថ្មីរបស់ក្រសួងព័ត៌មានអំពីគុណវុឌ្ឍិអ្នកសារព័ត៌មាន។ បើទោះបីវិធានការនេះត្រូវបានពណ៌នាថាមានគោលបំណងធានាស្តង់ដារអប្បបរមាផ្នែកគុណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយក៏ដោយ ប៉ុន្តែតាមពិតវាបានបន្ថែម ការរឹតត្បិតទៅលើសេរីភាពសារព័ត៌មានដែលមានស្រាប់ទៅវិញទេ។ ក្រសួងក៏បានដាក់ចេញតម្រូវការថ្មីសម្រាប់ស្នើសុំបណ្ណសារព័ត៌មាន ដោយទាមទារឱ្យអ្នកសារព័ត៌មានបង្ហាញលិខិតបញ្ជាក់កិរិយាមារយាទ លិខិតបញ្ជាក់ពីស្ថាប័នផ្សព្វផ្សាយថាមិនពាក់ព័ន្ធនឹងសំណុំរឿង ឬបណ្តឹងផ្លូវច្បាប់ ព្រមទាំងឯកសារបន្ថែមផ្សេងៗទៀត។[1]

វិធានការទាំងនេះបានបង្កក្តីព្រួយបារម្ភក្នុងចំណោមភាគីពាក់ព័ន្ធ ដោយសារវាអាចបង្កើនហានិភ័យនិងការរឹតត្បិតដែលអ្នកសារព័ត៌មានត្រូវប្រឈមមុខ ហើយបន្តបំផ្លាញបរិយាកាសប្រព័ន្ធផ្សព្វផ្សាយដែលមានភាពផុយស្រួយរួចទៅហើយ។ អ្នកការពារសិទ្ធិមនុស្ស និងអង្គការប្រព័ន្ធផ្សព្វផ្សាយ បានអំពាវនាវឱ្យក្រសួងព័ត៌មានពិនិត្យឡើងវិញលើតម្រូវការទាំងនេះ រៀបចំការពិគ្រោះយោបល់ដែលមានន័យពិតប្រាកដជាមួយភាគីពាក់ព័ន្ធ និងធានាថាក្របខណ្ឌបទប្បញ្ញត្តិមានតួនាទីការពារ មិនមែនដាក់កម្រិត លើសារព័ត៌មានឯករាជ្យនៅកម្ពុជា។[2]

ការវិវត្តន៍ទាំងនេះក៏បានបង្កើនការអនុវត្តការដាក់កំហិតលើខ្លួនឯង ក្នុងចំណោមអ្នកសារព័ត៌មានកម្ពុជា និងបន្ថែមការរឹតត្បិតលើសេរីភាពសារព័ត៌មាន ជាពិសេសបន្ទាប់ពីជម្លោះព្រំដែនដ៏ហិង្សារវាងកម្ពុជា និង ថៃ។

គិតត្រឹមខែតុលា ឆ្នាំ២០២៥ កម្ពុជាមានអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយដែលបានចុះបញ្ជី ចំនួន៨៧៣២នាក់ ក្នុងនោះស្ត្រីមាន១៣ភាគរយ។ ចំនួនអ្នកសារព័ត៌មានស្ត្រី ត្រូវបានរាយការណ៍ថា បានកើនឡើង៦ភាគរយ ប្រៀបធៀបនឹងឆ្នាំមុន។ បើតាមក្រសួងព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយដែលបាន ចុះបញ្ជីទូទាំងប្រទេសមានចំនួន១៥៥២។ ក្រសួងបានទទួលបណ្តឹងពាក់ព័ន្ធនឹងសកម្មភាពប្រព័ន្ធផ្សព្វផ្សាយចំនួន១០០ករណី។ ក្នុងនោះ បណ្តឹងចំនួន២៣ករណី ត្រូវបានរាយការណ៍ថា ត្រូវបានដោះស្រាយ ដើម្បីជៀសវាងការចាត់វិធានការផ្លូវច្បាប់លើអ្នកសារព័ត៌មាន។

ករណីទាំងនេះក៏បង្ហាញពីនិន្នាការនៃការប្រើប្រាស់យន្តការផ្លូវច្បាប់ដោយមិនត្រឹមត្រូវនៅតែបន្តមាន ដើម្បីដាក់គោលដៅលើអ្នកសារព័ត៌មាន។[3]

ការវិវត្តន៍ដែលបានរៀបរាប់ខាងលើ បង្ហាញពីការកើនឡើងនៃការគ្រប់គ្រងរបស់រដ្ឋលើប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា តាមរយៈវិធានការច្បាប់ បទប្បញ្ញត្តិ និងរដ្ឋបាល។ ទោះបីក្រសួងព័ត៌មានពន្យល់ថាវិធានការ ទាំងនេះមានគោល បំណងលើកកម្ពស់គុណភាពសារព័ត៌មាន ប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ ព្រមទាំងរក្សា សណ្តាប់ធ្នាប់សង្គមក៏ដោយ ជាសរុបវាបង្ហាញថា លំហប្រតិបត្តិការសម្រាប់សារព័ត៌មានឯករាជ្យនៅកម្ពុជា កំពុងត្រូវបានរួមតូច។ និន្នាការនេះមានផលប៉ះពាល់ជាខ្លាំងដល់គណនេយ្យភាពប្រជាធិបតេយ្យ សិទ្ធិទទួលបាន ព័ត៌មានរបស់សាធារណជន និងសុវត្ថិភាព ព្រមទាំងឯករាជ្យភាពរបស់អ្នកធ្វើការក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ។ បើគ្មានវិធានការបញ្ឈប់ការប្រើប្រាស់ច្បាប់ដោយមិនត្រឹមត្រូវ លុបចោលបទប្បញ្ញត្តិដែលមានលក្ខណៈរឹតត្បិត និងការពារអ្នកសារព័ត៌មានពីការសងសឹកទេ នោះលំហសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា នឹងបន្តរួមតូច ទៅទៀតទោះបីកើតឡើងដោយមិនសូវមើលឃើញជាសាធារណៈក៏ដោយ ប៉ុន្តែនឹងមានផលវិបាកធ្ងន់ធ្ងរចំពោះ គណនេយ្យភាព និងអភិបាលកិច្ចប្រជាធិបតេយ្យ។



រូបថត៖ ព្រីង សំរាំង

[1] https://cambojanews.com/information-minister-says-new-journalist-rules-only-for-newcomers-concerns-persist/

[2] https://www.facebook.com/story.php?story_fbid=1169073295429083&id=100069792703760&mibextid=wwXIfr&rdid=2EzihWkNwLwJwLYA#

[3] ទិន្នន័យទទួលបានពីអ្នកនាំពាក្យក្រសួងព័ត៌មាន លោក ទេព អស្នារិទ្ធ នៅក្នុងការប្រារព្ធទិវាអន្តរជាតិបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាននៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ ដែលរៀបចំឡើងដោយឧត្តមស្នងការអង្គការសហប្រជាជាតិ និងយូនីសស្កូ

# ៣. វិធីសាស្ត្រឃ្លាំមើលផ្អែកលើសិទ្ធិមនុស្ស

វិធីសាស្ត្រ និងការប្រមូលទិន្នន័យនៅក្នុងរបាយការណ៍នេះផ្តោតលើដំណោះស្រាយផ្អែកលើសិទ្ធិមនុស្សដើម្បីស្វែងយល់ និងឃ្លាំមើលការគំរាមកំហែង និងការវាយប្រហារមកលើសុវត្ថិភាពរបស់អ្នកសារព័ត៌មាន។

វិធីសាស្ត្រនេះទទួលស្គាល់ថាសកម្មភាពបែបនេះ មិនមែនត្រឹមតែប៉ះពាល់លើអ្នកសារព័ត៌មានជាលក្ខណៈ បុគ្គលទេប៉ុន្តែជាការរំលោភលើសិទ្ធិជាមូលដ្ឋាន ដែលជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ និង ប្រកបដោយ បរិយាប័ន្ន ។

ដូច្នេះ វិធីសាស្ត្រប្រមូលទិន្នន័យនេះគោរពតាមបទដ្ឋាន សិទ្ធិមនុស្សអន្តរជាតិ រួមមានការការពារ សេរីភាពនៃការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិជាមូលដ្ឋានផ្សេងៗទៀត ដូចជាសិទ្ធិរស់រាន មានជីវិត សិទ្ធិទទួលបានសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ដូចដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ICCPR)។ ចំណុចសំខាន់នៃវិធីសាស្ត្រនេះ គឺការយល់ដឹងអំពីការ ទទួលខុសត្រូវរបស់រដ្ឋ ក្នុងការគោរពការការពារ និងការបំពេញ លក្ខខណ្ឌសិទ្ធិមនុស្សស្របតាម ច្បាប់ស្តីពី សិទ្ធិមនុស្សអន្តរជាតិ ។ ការគំរាមកំហែង និង ការវាយប្រហារ ដែលផ្តោតគោលដៅមកលើអ្នកសារព័ត៌មាន និងស្ថាប័នព័ត៌មាន ដោយសារតែការបំពេញការងាររបស់ពួកគេត្រូវបានគេមើលឃើញថា ជាការរំលោភបំពានសិទ្ធិនៃការ បញ្ចេញមតិ ហើយសកម្មភាព នេះក៏ប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានព័ត៌មាន របស់សាធារណជន ផង ដែរ។

ដូច្នេះផ្នែកសំខាន់នៃក្របខណ្ឌឃ្លាំមើលនេះ គឺផ្តោតលើការកត់ត្រាការរំលោភលើសិទ្ធិសេរីភាពនៃការ បញ្ចេញមតិ និងការរំលោភបំពានពាក់ព័ន្ធផ្សេងទៀតលើសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលមាន សារៈសំខាន់ក្នុងការជួយអ្នកសារព័ត៌មានឱ្យបំពេញការងារដោយសេរី និង ដោយសុវត្ថិភាព ។ សិទ្ធិទាំង អស់នោះរួមមាន ៖

- សិទ្ធិក្នុងការរស់រានមានជីវិត
- ការការពារពី អំពើ ទារុណកម្ម និង ការប្រព្រឹត្តមកលើរាងកាយ ឬទណ្ឌកម្ម ឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប
- សិទ្ធិមានសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន រួមទាំងការការពារ ពីការឃុំខ្លួនទាំងបំពាន
- សិទ្ធិទទួលបានដំណោះស្រាយសមរម្យ
- សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌
- ការការពារពីការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន
- សិទ្ធិទទួលបានសមភាព និងមិនមានការរើសអើង

ហេតុដូច្នេះ វិធីសាស្ត្រប្រមូលទិន្នន័យ នៃរបាយការណ៍នេះការកត់ត្រាការគំរាមកំហែង និងការវាយ ប្រហារមកលើ អ្នកសារព័ត៌មាន ជាការរំលោភបំពានលើសិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការបញ្ចេញមតិ សិទ្ធិពលរដ្ឋ និង សិទ្ធិ នយោបាយសំខាន់ៗផ្សេងទៀតដូចដែលបានលើកជាឧទាហរណ៍ខាងលើ។ វិធីសាស្ត្រប្រមូល ទិន្នន័យនេះក៏អនុវត្តតាមសូចនាករស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន (JSIs) របស់អង្គការយូណេស្កូ និង ផែនការសកម្មភាពរបស់អង្គការសហប្រជាជាតិ ស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន និងបញ្ហា និទណ្ឌភាព (UNAP) ដែលជាគោលការណ៍អន្តរជាតិសំខាន់ៗដើម្បីវាយតម្លៃ ពីសុវត្ថិភាពរបស់ អ្នកសារព័ត៌ មាន ដោយរួមមានទិដ្ឋភាពច្បាប់ដែលទាក់ទងគ្នា សុវត្ថិភាពលើរាងកាយ ផ្លូវចិត្ត សុវត្ថិភាពអនឡាញ និង សុវត្ថិភាព ផ្អែកលើយេនឌ័រ ។

ផ្អែកលើគោលការណ៍ទាំងនេះ វិធីសាស្ត្រឃ្លាំមើលនេះបានរួមបញ្ចូលការយល់ដឹងផ្អែកយេនឌ័រ ដើម្បីបញ្ជាក់ ថាការគំរាមកំហែង និងការវាយប្រហារមកលើអ្នកសារព័ត៌មាន គឺជាការរំលោភបំពានសិទ្ធិមនុស្ស ។

## តើនរណា/អ្វីខ្លះ ត្រូវបានបញ្ចូលក្នុងទិន្នន័យនេះ?

ផ្អែកលើបទបញ្ញត្តិសិទ្ធិមនុស្សអន្តរជាតិ ការកំណត់និយមន័យដ៏ទូលំទូលាយ អំពីអ្នកសារព័ត៌មាន និង វិជ្ជាជីវៈសារព័ត៌មានត្រូវបានកំណត់ដោយគ្របដណ្តប់លើ៖

1. បុគ្គលដែលពាក់ព័ន្ធនឹងសកម្មភាពនៃការងារសារព័ត៌មាន ដើម្បីផ្តល់ដំណឹងដល់សាធារណជន អំពីបញ្ហាសំខាន់ៗដែលជាប្រយោជន៍សាធារណៈ ។
2. រាល់សកម្មភាពទាំងឡាយណា ដែលសំដៅមកលើបុគ្គលទាំងនោះ ជាគោលដៅនៃការគំរាម កំហែង ការបំភិតបំភ័យដោយសារតែសកម្មភាពសារព័ត៌មានរបស់ពួកគេគឺជា ការរំលោភលើ សិទ្ធិជាមូលដ្ឋាន ។

## ការចាត់ថ្នាក់ នៃការរំលោភសិទ្ធិមនុស្ស

វិធីសាស្ត្រនេះគ្របដណ្តប់លើការបំពានសិទ្ធិមនុស្សចំនួន៧ប្រភេទរួមមានការរំលោភលើសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសុវត្ថិភាពលើរាងកាយ សិទ្ធិទទួលបានសុវត្ថិភាពលើរាងកាយ និងសេរីភាពសិទ្ធិទទួលបានសុច្ចរិតភាព ផ្លូវចិត្ត សិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវ និង សេរីភាពក៏ដូចជាការរំលោភបំពាន ផ្សេងទៀតលើ សេរីភាព នៃការបញ្ចេញមតិ ។
ការរំលោភបំពាន ទាំងនេះក៏ត្រូវបានបែងចែងទៅតាមប្រភេទនៃការប្រព្រឹត្តបន្ថែមទៀតផងដែរ ដែលការប្រព្រឹត្តនោះ គឺស្ថិតក្នុងទម្រង់នៃការរំលោភបំពានសិទ្ធិមនុស្ស។

ពាក្យពេចន៍ ដែលកំណត់ន័យច្បាស់លាស់ ត្រូវបានបង្កើតឡើងសម្រាប់ប្រើប្រាស់ក្នុងការចាត់ថ្នាក់ និងការចាត់ថ្នាក់រង ជាប្រព័ន្ធចំពោះប្រភេទនៃការរំលោភបំពានទាំងនេះ ។ ពាក្យពេចន៍ទាំងនេះ គឺផ្អែកលើបទដ្ឋានសិទ្ធិមនុស្ស និងដកស្រង់ចេញពីប្រភពចម្រុះ រួមមានការចាត់ថ្នាក់បទឧក្រិដ្ឋអន្តរជាតិរបស់អង្គការសហប្រជាជាតិសម្រាប់គោលបំណងស្ថិតិ (ICCS)[4] សូចនាករនៃ គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាព (SDG) ១៦.១០.១[5] និង បទបញ្ញត្តិ សំខាន់ៗដែលចែងអំពីសិទ្ធិមនុស្ស[6]។

[4] ការបែងចែកប្រភេទឧក្រិដ្ឋកម្មអន្តរជាតិ គឺជាក្របខ័ណ្ឌមួយដើម្បីបែងចែក និងចាត់ថ្នាក់ជាប្រព័ន្ធ ប្រភេទឧក្រិដ្ឋកម្ម សម្រាប់គោលបំណងនៃការប្រមូលទិន្នន័យ ការវិភាគ និងការប្រៀបធៀបអន្តរជាតិ។ វាផ្តល់នូវវិធី សាស្ត្រស្តង់ដារសម្រាប់ចាត់ថ្នាក់ឧក្រិដ្ឋកម្មដល់ការគាំទ្រ ការប្រៀបធៀបទិន្នន័យ។ ករណីដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍នេះ ស្ថិតក្នុងការចាត់ថ្នាក់ឧក្រិដ្ឋកម្មអន្តរជាតិ រួមមានការចាប់ពិរុទ្ធ (ICCS 08031) ការឃុំខ្លួនដោយបំពាន (ICCS 020222) ការបៀតបៀនផ្លូវច្បាប់ (ICCS 0806) ការរើសអើង (ICCS 0210) និងការរំលោភបំពាន (ICCS 02011)។

[5] សូចនករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព 16.10.1 វាស់វែងការទទួលបានសិទ្ធិជាមូលដ្ឋានដែលគ្របដណ្តប់៖ «ចំនួនករណីដែលបានផ្ទៀងផ្ទាត់ ការសម្លាប់ ការចាប់ពង្រត់ ការបាត់ខ្លួនដោយបង្ខំ ការឃុំខ្លួនតាមអំពើចិត្ត និងការធ្វើទារុណកម្មលើអ្នកសារព័ត៌មាន បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ដែលពាក់ព័ន្ធ សហជីព និងអ្នកការពារសិទ្ធិមនុស្សក្នុងរយៈពេល ១២ខែមុន។» សូមមើល៖ https://www.ohchr.org/sites/default/files/Documents/Issues/ HRIndicators/SDG_Indicator_16_10_1_Guidance_Note.pdf

[6] បទបញ្ញត្តិសិទ្ធិមនុស្សទាំងនេះរួមមាន៖ សេចក្តីប្រកាសជាសកលនៃសិទ្ធិមនុសស (UDHR) កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិកម្មដ៏ឃោរឃៅ អមនុស្សធម៌ ឬថោកទាប (CAT)។

វាអាចត្រូវបានកត់សម្គាល់ថា ការរំលោភបំពានសិទ្ធិលើអ្នកសារព័ត៌មានអាចមានលក្ខណៈ ច្រើនប្រភេទ នៃការរំលោភសិទ្ធិមនុស្ស (ឧ. ការឃុំខ្លួន និងការបំពានលើរាងកាយ)។ សម្រាប់គោលបំណងនៃការចាត់ថ្នាក់ផ្នែកស្ថិតិ នៃករណីរំលោភបំពាន ខេមបូចា បានធ្វើការកំណត់អំពីប្រភេទ សិទ្ធិមនុស្សដែលត្រូវ បានរំលោភយ៉ាងធ្ងន់ធ្ងរបំផុត (ការរំលោភជាចម្បង)។ ព័ត៌មានអំពីការរំលោភបំពានបន្ថែម ឬការ រំលោភបំពាន ពាក់ព័ន្ធផ្សេងទៀត ដែលអ្នកសារព័ត៌មានដដែលបានជួបប្រទះ ត្រូវបានកត់ត្រាទុកក្នុង ប្រភពព័ត៌មានគុណភាព។

## ការប្រមូល និងការផ្ទៀងផ្ទាត់ទិន្នន័យ

ទិន្និន័យស្តីពីការរំលោភបំពានមកលើអ្នកសារព័ត៌មាន ដែលបញ្ចូលក្នុងរបាយការណ៍នេះ ត្រូវបានប្រមូល ដោយប្រើប្រាស់ព័ត៌មានចម្រុះទាំងពីប្រភពចម្បង និងប្រភពបន្ទាប់បន្សំ។ ទិន្នន័យពីប្រភពចម្បងត្រូវ បានប្រមូលតាមរយៈបទសម្ភាសជាមួយជនរងគ្រោះ សមាជិកគ្រួសាររបស់ពួកគេ និងសាក្សីហើយត្រូវ បានផ្ទៀងផ្ទាត់តាមរយៈការស្រាវជ្រាវឯកសារដែលមានស្រាប់។ ប្រភពបន្ទាប់បន្សំរួមមាន សេចក្តី រាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ព័ត៌មាននៅលើបណ្តាញសង្គម និងឯកសារផ្លូវការរបស់ តុលាការ។

ដើម្បីធានាបាននូវភាពត្រឹមត្រូវរាល់ទិន្នន័យទាំងអស់ត្រូវឆ្លងកាត់ដំណើរផ្ទៀងផ្ទាត់ជាមួយនឹងប្រភពច្រើន និងការត្រួតពិនិត្យជាប្រចាំ ។ ក្នុងករណីដែលអ្នកសារព័ត៌មានត្រូវ បានចោទប្រកាន់ពីបទកំហែងយក ខេមបូចាបានចាត់ទុកករណីទាំងនេះថាជាករណី រំលោភសិទ្ធិមនុស្ស លុះត្រាក្រោយពីបានធ្វើការស៊ើបអង្កេតឯករាជ្យ បានបង្ហាញនូវភស្តុតាងអំពីការគំរាមកំហែងការបំភិតបំភ័យ ឬសកម្មភាពផ្សេង ទៀត ដែលសំដៅធ្វើឱ្យប៉ះពាល់ដល់សេរីភាព សារព័ត៌មាន ។

នៅក្នុងហេតុផលអំពីសុវត្ថិភាព និងសន្តិសុខ ឈ្មោះអ្នកសារព័ត៌មាន ដែលរងផលប៉ះពាល់ និងប្រភពផ្សេងទៀតត្រូវបានដកចេញពីរបាយការណ៍នេះ ក្នុងករណីដែលព័ត៌មានទាំងនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ វិសាលភាពនិងដែនកំណត់របាយការណ៍នេះរាប់បញ្ចូលករណីរំលោភបំពានមកលើអ្នកសារព័ត៌មាន ដែត្រូវបានកត់ត្រាតាមរយៈ កិច្ចប្រឹងប្រែងឃ្លាំមើលរបស់ខេមបូចាតែប៉ុណ្ណោះ។ ដូច្នេះរបាយការណ៍នេះ មិនបានចងក្រងគ្រប់ករណី រំលោភបំពាន ទាំងអស់ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាអំឡុងពេលចងក្រងរបាយការណ៍នេះ ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ ២០២៥ នោះទេ។

វាក៏ប្រហែលជាមានករណីច្រើនទៀតដែលគេមិនបានរាយការណ៍ ជាពិសេសនៅតាមតំបន់មួយចំនួន នៅ តាមខេត្តទីដែលអ្នកសារព័ត៌មានជារឿយៗប្រឈមនឹងការយាយី ដោយគ្មានការឃ្លាំមើលការគាំទ្រ និង យន្តការការពារគ្រប់គ្រាន់។ ដូច្នេះលទ្ធផលដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះគ្រាន់តែជាផ្នែកមួយ ប៉ុណ្ណោះ ប៉ុន្តែជាព័ត៌មានឆ្លុះបញ្ចាំងអំពី និន្នាការទូលំទូលាយ និង ហានិភ័យ ដែលអ្នកសារព័ត៌មាននៅ កម្ពុជាកំពុងប្រឈម ។ សេរីភាពនៃការបញ្ចេញមតិ គឺជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ វាធានាថា បុគ្គលម្នាក់ៗអាចសម្តែងមតិទទួលបានព័ត៌មាន និងដាក់ឱ្យអ្នកមានអំណាចទទួលខុសត្រូវ ដោយគ្មានការភ័យខ្លាចអំពីការចាប់ពិរុទ្ធឬការសងសឹក។ នៅពេលដែលសារព័ត៌មានត្រូវបានចាប់ពិរុទ្ធ ឬ រឹតត្បិត វាបង្កើតឱ្យមានការរំលោភបំពានដោយផ្ទាល់លើសិទ្ធិជាមូលដ្ឋាន ដែលត្រូវបានធានាក្នុងមាត្រា១៩ ទាំងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (UDHR មាត្រា១៩ ICCPRមាត្រា១៩ (១); ១៩ (២))





សេរីភាពនៃការបញ្ចេញមតិ គឺជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ វាធានាថា បុគ្គលម្នាក់ៗអាចសម្តែងមតិទទួលបានព័ត៌មាន និងដាក់ឱ្យអ្នកមានអំណាចទទួលខុសត្រូវ ដោយគ្មានការភ័យខ្លាចអំពីការចាប់ពិរុទ្ធ ឬការសងសឹក។ នៅពេលដែលសារព័ត៌មានត្រូវបានចាប់ពិរុទ្ធ ឬ រឹតត្បិត វាបង្កើតឱ្យមានការរំលោភបំពានដោយផ្ទាល់លើសិទ្ធិជាមូលដ្ឋាន ដែលត្រូវបានធានាក្នុងមាត្រា១៩ ទាំងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (UDHR មាត្រា ១៩ ICCPR មាត្រា១៩ (១); ១៩ (២))

### មាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ( UDHR )

មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់។ សិទ្ធិនេះ រាប់ទាំងសេរីភាពក្នុងការប្រកាន់យកមតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយបញ្ចេញមតិបែបណាមួយក៏ដោយ។

### មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

1. មនុស្សគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។
2. មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំង សេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយៈផ្ទាល់មាត់ សរសេរ ឬបោះពុម្ព ទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។
3. ការប្រើប្រាស់សិទ្ធិ ដែលមានចែងក្នុងកថាខណ្ឌ ២ នៃមាត្រានេះ តម្រូវឱ្យមានករណីយកិច្ចនិងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិvអាចមានការរឹតត្បិតមួយចំនួនដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បីៈ
   (ក) គោរពសិទ្ធិ និងកិត្តិសព្ទអ្នកដទៃ។
   (ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។

# ៤. ការរកឃើញសំខាន់ៗ

ចន្លោះពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៥ ខេមបូចា បានកត់ត្រាករណីរំលោភសិទ្ធិមនុស្សលើអ្នកសារព័ត៌មានចំនួន១៤ករណី ដែលក្នុងនោះមានអ្នកសារព័ត៌មានស្ត្រី៤នាក់។ ចំនួនករណីរំលោភបំពានលើអ្នកសារព័ត៌មានស្ត្រីដែលបានកត់ត្រាក្នុងត្រីមាសនេះ មានចំនួនខ្ពស់ជាងត្រីមាសមុនៗ។

ក្នុងចំណោមករណីរំលោភបំពានលើអ្នកសារព័ត៌មានស្ត្រី មានករណីមួយជាករណីលេចធ្លោមួយ ដែលពាក់ព័ន្ធនឹងអំពើហិង្សាផ្អែកលើយេនឌ័រដោយអ្នកសារព័ត៌មានស្ត្រីរូបនោះបានរងការបំពានជាច្រើនទម្រង់រួមមានការបៀតបៀនផ្លូវភេទទាំងលើរាងកាយ និងពាក្យសំដីនៅកន្លែងការងារ ព្រមទាំងទទួលរងការបញ្ចប់កិច្ចសន្យាការងារដែលផ្ទុយនឹងច្បាប់ការងារទៀតផង។

ករណីរំលោភបំពានចំនួន១៤ដែលបានកត់ត្រា បានកើតឡើងក្នុងហេតុការណ៍ដាច់ដោយឡែកគ្នាចំនួន១០ ដែលមានន័យថាអ្នកសារព័ត៌មានច្រើននាក់បានរងការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធនឹងហេតុការណ៍តែមួយឬក្នុងអំឡុងពេលរាយការណ៍អំពីព្រឹត្តិការណ៍ព័ត៌មានតែមួយ។

ករណីរំលោភសិទ្ធិ ដែលបានកត់ត្រាក្នុងត្រីមាសនេះ មានការថយចុះ៣៩ភាគរយ បើប្រៀបធៀបនឹងត្រីមាសមុន (ខែកក្កដា-កញ្ញា) ដែលមានការកត់ត្រាករណីរំលោភបំពានរហូតដល់ចំនួន២៣។ ទោះជាយ៉ាងណាការថយចុះនេះ មិនមានន័យថាស្ថានភាពសេរីភាពសារព័ត៌មានមានភាពប្រសើរឡើងឡើយ។ ផ្ទុយទៅវិញករណីដែលបានកត់ត្រាទាំងអស់ បង្ហាញថាស្ថានភាពប្រព័ន្ធផ្សព្វផ្សាយកាន់តែរឹតត្បិតឡើង ដែលអាចមើលឃើញតាមរយៈការគ្រប់គ្រងតាមបទប្បញ្ញត្តិ ការបំភ័យតាមផ្លូវច្បាប់ និងការដាក់កំហិតលើខ្លួនឯងជាដើម។

ប្រកាសថ្មីមួយរបស់រដ្ឋាភិបាលស្តីពីគុណវុឌ្ឍិអ្នកសារព័ត៌មាន បានរឹតបន្តឹងយ៉ាងខ្លាំងលើលក្ខខណ្ឌសម្រាប់ការទទួលបានបណ្ណសំគាល់អ្នកសារព័ត៌មាន ដែលកាន់តែដាក់កំហិតបន្ថែមទៀតលើសារព័ត៌មានឯករាជ្យ។ បច្ចុប្បន្នអ្នកសារព័ត៌មានត្រូវបង្ហាញលិខិតបញ្ជាក់កិរិយាមារយាទពីអាជ្ញាធរមូលដ្ឋាន លិខិតបញ្ជាក់ពីស្ថាប័នព័ត៌មានថាមិនពាក់ព័ន្ធនឹងករណីផ្លូវច្បាប់ឬ ការតវ៉ាជាអាទិ៍លើអត្ថបទ ឬវីដេអូ ឬរូបភាព ឬវប្បធម៌ ឬក្បួនខ្នាតអក្សរសាស្រ្តនិងភាសាជាតិខ្មែរ ដែលរំលោភទៅលើក្រមសីលធម៌វិជ្ជាជីវៈជាដើម ព្រមទាំងឯកសារបន្ថែមផ្សេងៗទៀត។ តម្រូវការទាំងនេះ ផ្តល់អំណាចសម្រេចចិត្តយ៉ាងធំដល់អាជ្ញាធរ ក្នុងការគ្រប់គ្រងថានរណាអាចអនុវត្តវិជ្ជាជីវៈសារព័ត៌មានដោយស្របច្បាប់បាន។

ករណីចំនួន៨ ដែលបានកត់ត្រាបានប៉ះពាល់ដោយផ្ទាល់ដល់សុវត្ថិភាពផ្លូវច្បាប់របស់អ្នកសារព័ត៌មាន ដែលស្មើនឹង៥៧% នៃករណីរំលោភបំពានសរុប(សូមមើលតារាងទី១)។ ក្នុងនោះរួមមានករណីឃាត់ខ្លួនចំនួន៧ ដោយអ្នក សារព័ត៌មានត្រូវបានចាប់ខ្លួនសាកសួរដោយអាជ្ញាធរមូលដ្ឋាន ខណៈពេលរាយការណ៍អំពីជម្លោះព្រំដែនកម្ពុជា-ថៃ។ បន្ថែមពីនេះ ក៏មានករណីបៀតបៀនផ្លូវច្បាប់ចំនួន១ ត្រូវបានកត់ត្រាផងដែរ។ ករណីនេះពាក់ព័ន្ធនឹងអ្នកសារព័ត៌មានម្នាក់ត្រូវបានកោះហៅ និងដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយនគរបាលខេត្ត។





ករណីរំលោភបំពានលើសុវត្ថិភាពរាងកាយចំនួន៤ ត្រូវបានកត់ត្រា។ ករណីទាំងនេះរួមមាន៖ អ្នកសារព័ត៌មានម្នាក់រងរបួសដោយសារការគ្រាប់ផ្លោងក្នុងអំឡុងពេលរាយការណ៍អំពីជម្លោះកម្ពុជា-ថៃ ករណីបៀតបៀនផ្លូវភេទលើអ្នកសារព័ត៌មានស្ត្រីម្នាក់ ករណីហិង្សាលើអ្នកសារព័ត៌មានចំនួន១ និងករណីគំរាមកំហែងនឹងបង្កហិង្សាលើរាងកាយចំនួន១ករណី។

អ្នកសារព័ត៌មានដែលរងអំពើហិង្សា បានដាក់ពាក្យបណ្តឹងទៅនគរបាល។ ចំណែកករណីបៀតបៀនផ្លូវភេទវិញ អ្នកសារព័ត៌មានដែលរងគ្រោះបានរាយការណ៍អំពីហេតុការណ៍នេះទៅអង្គការការពារសិទ្ធិមនុស្ស ស្ថាប័នសារព័ត៌មានដែលគាត់បម្រើការងារ ព្រមទាំងខេមបូចាផងដែរ។

ពាក់ព័ន្ធនឹងករណីបៀតបៀនផ្លូវភេទ ជនដែលត្រូវបានចោទប្រកាន់ថាពាក់ព័ន្ធ មិនត្រូវបាននាំខ្លួនឱ្យទទួលខុសត្រូវឡើយ។ ផ្ទុយទៅវិញ ជនរងគ្រោះបែរជាត្រូវបាននិយោជកបញ្ចប់កិច្ចសន្យាការងារ ដោយគ្មានសំណងដែលផ្ទុយនឹងច្បាប់ការងារថែមទៀតផង។

ការរកឃើញក្នុងត្រីមាសនេះ បង្ហាញថាអ្នកសារព័ត៌មានដែលបម្រើការនៅស្ថាប័នប្រព័ន្ធផ្សព្វផ្សាយអនឡាញជាក្រុមដែលរងការរំលោភបំពានញឹកញាប់ជាងគេ។ ទិន្នន័យនេះស្របគ្នាទៅនឹងនិន្នាការទូទៅដែលបង្ហាញពីការកើនឡើងនៃការតាមដានឃ្លាំមើលលើប្រព័ន្ធអនឡាញ និងហានិភ័យកាន់តែខ្ពស់ពាក់ព័ន្ធនឹងការប្រើប្រាស់វេទិកាឌីជីថលសម្រាប់ការរាយការណ៍ព័ត៌មានឯករាជ្យ។

ដូចគ្នានឹងត្រីមាសមុន ការរាយការណ៍អំពីជម្លោះព្រំដែនកម្ពុជា-ថៃ នៅតែជាមូលហេតុសំខាន់នៃការរំលោភបំពានលើអ្នកសារព័ត៌មាន។ ការរំលោភបំពានចំនួន៥០% (សរុបចំនួន៧ករណី) ដែល ខេមបូចា បានកត់ត្រាមានការពាក់ព័ន្ធដោយផ្ទាល់នឹងព្យាយាមក្នុងក្នុងការគ្រប់គ្រងការរាយការណ៍ពីជម្លោះនេះពីសំណាក់អាជ្ញាធរ។ ដែលជាញឹកញាប់ត្រូវបានលើកឡើងដោយយោងហេតុផលសន្តិសុខជាតិ។ ការផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើជម្លោះព្រំដែន ក៏បានធ្វើឱ្យការរាយការណ៍លើប្រធានបទរសើបផ្សេងទៀតថយចុះផងដែរ ព្រោះអ្នកសារព័ត៌មានព្រួយបារម្ភពីការសងសឹក ខណៈការចាប់អារម្មណ៍របស់សាធារណជននៅតែផ្តោតលើជម្លោះព្រំដែន។

ក្នុងត្រីមាសទីបួនឆ្នាំ២០២៥នេះ ខេមបូចាក៏បានកត់ត្រាករណីរំលោភបំពានលើអ្នកសារព័ត៌មានដដែល ដែលត្រូវបានកត់ត្រាបន្តពីត្រីមាសមុនៗ។ ករណីនេះបង្ហាញថាសម្ពាធនិងការបៀតបៀនតាមផ្លូវច្បាប់ដែលបន្តអូសបន្លាយ អាចត្រូវបានប្រើជាវិធានការបង្ខិតបង្ខំ ទោះបីមិនមានសាលក្រមផ្តន្ទាទោសក៏ដោយ ដើម្បីបង្កើនការភ័យខ្លាច និងជំរុញឱ្យអ្នកសារព័ត៌មានដាក់កំហិតលើខ្លួនឯង។

## ការរកឃើញទាំងនេះឆ្លុះបញ្ចាំង៖

1. ការប្រើប្រាស់នីតិវិធីច្បាប់និងតុលាការមិនត្រឹមត្រូវ ដើម្បីបំបិទសំឡេងអ្នកសារព័ត៌មាន ផ្តន្ទាទោសលើការរាយការណ៍បែបរិះគន់ និងបង្អាក់អ្នកសារព័ត៌មានពីការរាយការណ៍លើបញ្ហាដែលពាក់ព័ន្ធផលប្រយោជន៍សាធារណៈ។
2. បរិយាកាសប្រព័ន្ធផ្សព្វផ្សាយដែលកាន់តែរឹតត្បិត ដែលត្រូវបានដាក់កំហិតថែមទៀតតាមរយៈការគ្រប់គ្រងតាមបទប្បញ្ញត្តិ ការបំភ័យតាមផ្លូវច្បាប់ និងការដាក់កំហិតលើខ្លួនឯង។

3. ការលើកយកហេតុផលសន្តិសុខជាតិពាក់ព័ន្ធនឹងជម្លោះព្រំដែនកម្ពុជា-ថៃ មកប្រើដើម្បីបង្ហាញពីភាពស្របច្បាប់នៃការដាក់កំហិត រឹតត្បិតការចូលទៅយកព័ត៌មាន និងរាំងការត្រួតពិនិត្យដោយឯករាជ្យ។
4. ទំនាក់ទំនងរវាងការបំពាននៅកន្លែងការងារ និងកង្វះវិធានការការពារប្រកបដោយប្រសិទ្ធភាពសម្រាប់អ្នកសារព័ត៌មានស្ត្រី។

ដូចដែលបានបង្ហាញក្នុងតារាងទី១ ករណីរំលោភបំពានដែលបានកត់ត្រាក្នុងអំឡុងពេលនេះ គ្របដណ្តប់លើទិដ្ឋភាពសុវត្ថិភាពសំខាន់ៗចំនួន ៤ រួមមាន សុវត្ថិភាពផ្លូវច្បាប់ សុវត្ថិភាពរាងកាយ សុវត្ថិភាពផ្លូវចិត្ត និងការរំលោភបំពានសិទ្ធិផ្សេងៗទៀតលើសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ។

**តារាងទី១៖ ការបែងចែកការរំលោភបំពានសិទ្ធិទៅតាមទិដ្ឋភាពសុវត្ថិភាព (ខែតុលា-ធ្នូ)**

| ទិដ្ឋភាពសុវត្ថិភាព | ចំនួន ករណីរំលោភបំពាន | ចំនួនឧប្បត្តិហេតុ |
|---|---|---|
| ផ្នែកផ្លូវច្បាប់ | ៨ | ៤ |
| ផ្នែករាងកាយ | ៤ | ៤ |
| ផ្នែកផ្លូវចិត្ត | ១ | ១ |
| ការរំលោភបំពានសិទ្ធិផ្សេងៗទៀតលើសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ | ១ | ១ |
| **Total** | ១៤ | ១០ |

តារាងទី២ បង្ហាញលម្អិតពីប្រភេទនិងភាពញឹកញាប់នៃការរំលោភសិទ្ធិមនុស្ស និងសកម្មភាពដែលបានកត់ត្រាក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ ដូចដែលបានបង្ហាញ មានការរំលោភបំពានសិទ្ធិមនុស្សសំខាន់ៗចំនួនប្រាំប្រភេទ ដែលរួមមានការរំលោភបំពានមកលើសិទ្ធិទទួលបានសុវត្ថិភាពលើរាងកាយ សិទ្ធិទទួលបានសុខុមាលភាពផ្លូវចិត្ត សិទ្ធិទទួលបានយុត្តិធម៌ សិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវនិងសេរីភាព និងការរំលោភបំពានសិទ្ធិផ្សេងៗទៀតលើសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ។ ដូចដែលបង្ហាញក្នុងតារាងទី២ ប្រភេទការរំលោភដែលកើតឡើងញឹកញាប់ជាងគេប៉ះពាល់ដល់អ្នកសារព័ត៌មាន គឺការរំលោភលើសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវ និង សេរីភាព(សរុបមានករណីរំលោភបំពានចំនួន៧)។





**តារាងទី ២៖ ប្រភេទ និងភាពញឹកញាប់នៃការរំលោភសិទ្ធិមនុស្ស និងសកម្មភាពដែលបានកត់ត្រា (ខែតុលា-ធ្នូ)**

| ប្រភេទនៃការរំលោភសិទ្ធិមនុស្ស | សកម្មភាពដែលត្រូវបានរាប់បញ្ចូល | ប្រភេទនៃសកម្មភាព | ចំនួនករណី |
|---|---|---|---|
| សិទ្ធិទទួលបានសុវត្ថិភាពលើរាងកាយ | សកម្មភាពទាក់ទងនឹងការងារសារព័ត៌មានដែលបណ្តាលឱ្យមាន (ការវាយប្រហារ) របួសស្នាមលើរាងកាយ ឬមានចេតនា (ការគំរាមកំហែង) បង្កឱ្យមានរបួសស្នាមលើរាងកាយ។ | ហិង្សាលើរាងកាយ | ១ |
| | | ការបៀតបៀនផ្លូវភេទ | ១ |
| | | រងរបួសក្នុងពេលមានជម្លោះព្រំដែន | ១ |
| | | ការគំរាមកំហែងនឹងបង្កហិង្សាលើរាងកាយ | ១ |
| សិទ្ធិទទួលបានសុខុមាលភាពផ្លូវចិត្ត | សកម្មភាពគំរាមកំហែង ឬធ្វើឱ្យប៉ះពាល់ផ្លូវចិត្ត ដែលទាក់ទងនឹងការងារសារព័ត៌មាន | ការបំភិតបំភ័យ | ១ |
| សិទ្ធិទទួលបានយុត្តិធម៌ | សំដៅដល់វិធានការផ្លូវច្បាប់ក្នុងចេតនាបំបាក់ទឹកចិត្ត រឹតត្បិត ឬគ្រប់គ្រងលើការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន | ការឃាឃីតាមផ្លូវច្បាប់ | ១ |
| សិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវនិងសេរីភាព | សំដៅដល់វិធានការផ្លូវច្បាប់ក្នុងចេតនាបំបាក់ទឹកចិត្តរឹតត្បិត ឬគ្រប់គ្រងលើការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន | ការឃាត់ខ្លួន | ៧ |
| ការរំលោភបំពានផ្សេងៗទៀតលើសិទ្ធិសេរីភាពបញ្ចេញមតិ | សកម្មភាពដែលចាត់ទុកថាជាការដាក់កំហិតឬការគ្រប់គ្រងលើការបង្ហាញមតិសារព័ត៌មានដែលមិនបានរាប់បញ្ចូលនៅផ្នែកផ្សេងទៀត | មិនអនុញ្ញាតឱ្យចូលយកព័ត៌មាន | ១ |
| សរុប | | | ១៤ |

ទាក់ទងនឹងការរំលោភបំពានលើសិទ្ធិទទួលបានសុវត្ថិភាពលើរាងកាយ អ្នកសារព័ត៌មានម្នាក់នៅឧត្តរមានជ័យបានរងរបួសធ្ងន់ធ្ងរដោយសារអំបែងគ្រាប់ផ្លោងរបស់យោធាថៃក្នុងពេលកំពុងរាយការណ៍អំពីការប៉ះទង្គិចគ្នាតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ករណីនេះបង្ហាញពី កង្វះវិធានការសុវត្ថិភាព ឬការការពារគ្រប់គ្រាន់សម្រាប់អ្នកសារព័ត៌មានដែលរាយការណ៍ព្រឹត្តិការណ៍ទាក់ទងនឹងជម្លោះព្រំដែន។[7] នៅខេត្តកណ្តាល ចាងហ្វាងសារព័ត៌មានមួយត្រូវបានអភិបាលរងខេត្តម្នាក់រុញច្រាន ខណៈពេលកំពុងផ្សាយផ្ទាល់ពីការតវ៉ាជាសាធារណៈដែលនេះបង្ហាញពីការប្រើប្រាស់អំណាចដោយរំលោភបំពានដើម្បីបំបិទសំឡេងអ្នកសារព័ត៌មាន។[8]

ខេមបូចា ក៏បានកត់ត្រាករណីបៀតបៀនផ្លូវភេទមួយដែលកើតឡើងនៅកន្លែងធ្វើការទៅលើអ្នកសារព័ត៌មានស្ត្រីម្នាក់ដែលគាត់បានរងការបៀតបៀនទាំងផ្លូវកាយ និងពាក្យសំដី។[9] ក្នុងហេតុការណ៍មួយផ្សេងទៀត អ្នកសារព័ត៌មានស្ត្រីម្នាក់ទៀតត្រូវបានគេគំរាមកំហែងនឹងបង្កហិង្សានៅផ្ទះរបស់គាត់នៅពេលយប់ ក្រោយពីគាត់បានចេញផ្សាយសេចក្តីរាយការណ៍ពីការសង្ស័យរឿងរ៉ែខុសច្បាប់។ ការវាយប្រហារនោះបានធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ និងរបស់របរផ្ទាល់ខ្លួនរបស់អ្នកសារព័ត៌មានរូបនោះទៀតផង។[10]

ការឃាត់ខ្លួនតាមអំពើចិត្ត នៅតែជាការរំលោភសិទ្ធិចម្បងទៅលើសិទ្ធិសេរីភាពរបស់អ្នកសារព័ត៌មាន។ មានករណីសរុបចំនួន៧ត្រូវបានកត់ត្រាទាក់ទងនឹងការឃាត់ខ្លួន។ ក្នុងចំណោមនោះ អ្នកសារព័ត៌មាន៦នាក់ត្រូវបានឃាត់ខ្លួនសាកសួរ និងរឹបអូសសម្ភារៈបណ្តោះអាសន្ន ខណៈពេលកំពុងរាយការណ៍រឿងស្ពានដែលរងការខូចខាតដោយគ្រាប់បែករបស់ថៃ និងជំរំជនភៀសខ្លួននៅក្បែរនោះ ដែលទីតាំងនោះស្ថិតនៅខេត្តឧត្តរមានជ័យ។ នគរបាលបានចោទថាអ្នកសារព័ត៌មានទាំងនោះមិនមានឯកសារនៃការអនុញ្ញាតត្រឹមត្រូវក្នុងការរាយការណ៍ និងបានដាក់ការសង្ស័យថាពួកគេពាក់ព័ន្ធនឹងអំពើចារកម្ម។[11] នៅខេត្តកំពត ចាងហ្វាងផ្សាយម្នាក់ត្រូវបានចាប់ខ្លួន និងឃាត់ខ្លួន បន្ទាប់ពីរាយការណ៍ពីការគ្រប់គ្រងផ្សារមួយនៅមូលដ្ឋានដែលត្រូវបានចោទថាមានភាពមិនប្រក្រតី។ លោកត្រូវបានដោះលែងវិញ បន្ទាប់ពីថតវីដេអូសុំទោសជាសាធារណៈនៅប៉ុស្តិ៍រដ្ឋបាលនគរបាលឃុំ។[12]

នៅខេត្តបន្ទាយមានជ័យ ចាងហ្វាងផ្សាយម្នាក់ ក៏រងការរំលោភបំពានសិទ្ធិដោយប្រើប្រាស់ផ្លូវច្បាប់ផងដែរ ដោយត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ក្នុងសំណុំរឿងពាក់ព័ន្ធនឹងការរាយការណ៍អំពីភាពមិនប្រក្រតីរបស់នគរបាល ដែលចាត់ទុកថានេះជាទម្រង់មួយនៃការបៀតបៀនតាមផ្លូវច្បាប់។[13]
ក្នុងករណីមួយផ្សេងទៀត អ្នកសារព័ត៌មានស្ត្រីម្នាក់ដែលរាយការណ៍អំពីការរំលោភសិទ្ធិកម្មករ បានទទួលសារប្រមាថនិងការគំរាមកំហែងតាមផ្លូវច្បាប់ បន្ទាប់ពីគាត់បដិសេធមិនបង្ហាញប្រភពព័ត៌មានរបស់ខ្លួន។[14] ពាក់ព័ន្ធនឹងការរំលោភសិទ្ធិផ្សេងៗទៀតលើសិទ្ធិទទួលបានសេរីភាពក្នុងការបញ្ចេញមតិ ការរឹតត្បិតលើការចូលទៅកាន់ទីតាំងសាធារណៈ(មិនអនុញ្ញាតឱ្យចូល) និងយកព័ត៌មាន បានកើតឡើងនៅរាជធានីភ្នំពេញ នៅពេលអ្នកសារព័ត៌មានវិទ្យុម្នាក់ ត្រូវបានសន្តិសុខឯកជនរារាំងមិនឱ្យថតពីកម្រិតទឹកទន្លេមេគង្គដែលកំពុងកើនឡើង ហើយបានព្រមានឱ្យចាកចេញពីទីតាំងនោះ បើពុំដូច្នោះទេគេនឹងចាត់វិធានការ។[15]

[7]សម្រាប់ព័ត៌មានលំអិតសូមមើលឧបសម្ព័ន្ធករណីលេខ២
[8]សម្រាប់ព័ត៌មានលំអិតសូមមើលឧបសម្ព័ន្ធករណីលេខ៥
[9]សម្រាប់ព័ត៌មានលំអិតក្នុងករណីត្រូវបានបង្ហាញដើម្បីគោរពគោលការណ៍មិនធ្វើឱ្យអ្នកសារព័ត៌មានរងការឈឺចាប់ឬសងសឹក
[10]សម្រាប់ព័ត៌មានលំអិតសូមមើលឧបសម្ព័ន្ធករណីលេខ៤
[11]សម្រាប់ព័ត៌មានលំអិតសូមមើលឧបសម្ព័ន្ធករណីលេខ១
[12]សម្រាប់ព័ត៌មានលំអិតសូមមើលឧបសម្ព័ន្ធករណីលេខ៣
[13]សម្រាប់ព័ត៌មានលំអិតសូមមើលឧបសម្ព័ន្ធករណីលេខ៦
[14]សម្រាប់ព័ត៌មានលំអិតក្នុងករណីត្រូវបានបង្ហាញដើម្បីគោរពគោលការណ៍មិនធ្វើឱ្យអ្នកសារព័ត៌មានរងការឈឺចាប់ឬសងសឹក
[15]សម្រាប់ព័ត៌មានលំអិតសូមមើលឧបសម្ព័ន្ធករណីលេខ៧



របាយការណ៍ឃ្លាំមើលប្រចាំត្រីមាស

ចំពោះទីតាំងកើតហេតុករណីរំលោភបំពានភាគច្រើនបំផុតកើតឡើងនៅខេត្តឧត្តរមានជ័យ(សូមមើលតារាងទី៣)។

**តារាងទី៣៖ ទីតាំងដែលត្រូវបានរាយការណ៍អំពីឧប្បត្តិហេតុនិងការរំលោភបំពានសិទ្ធិមនុស្សទៅលើអ្នកសារព័ត៌មាន**

| រាជធានី/ខេត្ត | ចំនួនការរំលោភសិទ្ធិ | ចំនួន ឧប្បត្តិហេតុ |
|---|---|---|
| ឧត្តរមានជ័យ | ៧ | ៣ |
| ភ្នំពេញ | ២ | ២ |
| បន្ទាយមានជ័យ | ១ | ១ |
| កណ្តាល | ១ | ១ |
| មណ្ឌលគិរី | ១ | ១ |
| កំពត | ១ | ១ |
| កំពង់ស្ពឺ | ១ | ១ |
| សរុប | ១៤ | ១០ |

ក្នុងចំណោមឧប្បត្តិហេតុចំនួន១០ (ប៉ះពាល់ដល់អ្នកសារព័ត៌មាន ១៤នាក់) ដែលបានកត់ត្រាមានករណីចំនួន៦ត្រូវបានាប្រព្រឹត្តដោយតួអង្គរដ្ឋ។ អ្នកពាក់ព័ន្ធទាំងនេះ ត្រូវបានចាត់ថ្នាក់តាមបីកម្រិត រួមមាន៖ កម្រិតខេត្ត ២ករណី (អភិបាលរងខេត្ត និងនគរបាលខេត្ត) និងកម្រិតមូលដ្ឋាន៣ករណី (នគរបាលស្រុក)។ ក្នុងហេតុការណ៍មួយ អ្នកសារព័ត៌មានម្នាក់បានរងរបួសដោយសារអំបែងគ្រាប់ដែលពាក់ព័ន្ធនឹងជម្លោះរវាងកម្ពុជា និងថៃ។

ករណីចំនួន៤ ពាក់ព័ន្ធនឹងតួអង្គឯកជន(សន្តិសុខឯកជននិងបុគ្គលម្នាក់) ដែលបានចាត់វិធានការសងសឹកបន្ទាប់ពីមានការរាយការណ៍អំពីសកម្មភាពជីកយករ៉ែនិងការឡើងកម្រិតទឹកទន្លេមេគង្គ។ ក្នុងចំណោមនោះ មានករណីមួយជាអំពើហិង្សាផ្អែកលើយេនឌ័រ ដែលអ្នកសារព័ត៌មានស្ត្រីម្នាក់រងការបៀតបៀនផ្លូវភេទដោយអ្នកគ្រប់គ្រងរបស់គាត់។

ការរំលោភបំពានភាគច្រើនដែលប្រព្រឹត្តិដោយតួអង្គរដ្ឋ បង្ហាញពីការរឹតត្បិតជាបន្តបន្ទាប់លើសេរីភាពបញ្ចេញមតិនិងសេរីភាពសារព័ត៌មានដែលជាការបំពានយ៉ាងច្បាស់លើកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិនិងរួមចំណែកបន្តឱ្យមានវប្បធម៌និទណ្ឌភាព។ ទិន្នន័យក៏បង្ហាញថាករណីរំលោភបំពានទាំងនេះភាគច្រើនពាក់ព័ន្ធនឹងការរាយការណ៍លើប្រធានបទរសើប រួមមានជម្លោះព្រំដែនកម្ពុជា-ថៃ បញ្ហាគណនេយ្យភាពសង្គម បញ្ហារ៉ែ សិទ្ធិកម្មករ និងការតវ៉ាជាសាធារណៈជាដើម។

# ៥. សេចក្តីសន្និដ្ឋាន

ការរកឃើញរបស់ខេមបូចាក្នុងត្រីមាសទីបួន ឆ្នាំ២០២៥នេះ បង្ហាញពីការធ្លាក់ចុះជាប្រព័ន្ធនិងបន្តបន្ទាប់នៃសេរីភាពសារព័ត៌មាននៅកម្ពុជា។ សារព័ត៌មានឯករាជ្យកំពុងដំណើរការនៅក្នុងបរិយាកាសដែលកាន់តែរឹតត្បិត ដែលបណ្តាលមកពីការពង្រឹកការគ្រប់គ្រងតាមបទប្បញ្ញត្តិ ការបំភិតបំភ័យតាមផ្លូវច្បាប់ និងការរំលោភបំពានលើអ្នកសារព័ត៌មានដែលនៅតែបន្តកើតមាន។ វិធានការដែលដាក់ចេញដោយក្រសួងព័ត៌មាន ជាពិសេសប្រកាសថ្មីស្តីពីគុណវុឌ្ឍិសារព័ត៌មាន និងតម្រូវការកាន់តែតឹងរ៉ឹងក្នុងការទទួលបានបណ្ណសារព័ត៌មាន បានបង្កើតឧបសគ្គបន្ថែមទៀតចំពោះការងារសារព័ត៌មាន និងបង្កើនហានិភ័យនៃការឃាត់ខ្លួនតាមអំពើចិត្ត ការសងសឹក និងការដាក់កំហិតលើខ្លួនឯង។ ទោះបីវិធានការទាំងនេះត្រូវបានពណ៌នាថាមានគោលបំណងលើកកម្ពស់វិជ្ជាជីវៈ និងសណ្តាប់ធ្នាប់សង្គមក៏ដោយ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង វាបានបង្រួមលំហសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យឱ្យកាន់តែតូចចង្អៀតទៅវិញ។

ករណីរំលោភបំពានចំនួន១៤ លើអ្នកសារព័ត៌មាន ដែលបានកត់ត្រាក្នុងត្រីមាសនេះ បង្ហាញពីផលវិបាកជាក់ស្តែងលើសិទ្ធិមនុស្ស ដែលកើតចេញពីបរិយាកាសបែបនេះ។ អ្នកសារព័ត៌មានបានប្រឈមនឹងការវាយប្រហារ និងការគំរាមកំហែងលើរាងកាយ អំពើហិង្សាផ្អែកលើយេនឌ័រ ការចាប់ខ្លួននិងឃាត់ទុកតាមអំពើចិត្ត ព្រមទាំងការបំភ័យតាមផ្លូវច្បាប់ ដែលភាគច្រើនពាក់ព័ន្ធនឹងតួអង្គរដ្ឋជាពិសេសអាជ្ញាធរមូលដ្ឋាន។ ការរំលោភបំពានទាំងនេះ ផ្ទុយនឹងរដ្ឋធម្មនុញ្ញនិងកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ជាពិសេសក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ខណៈដែលការបន្តប្រើប្រាស់ក្រមព្រហ្មទណ្ឌ ជំនួសឱ្យដំណោះស្រាយតាមបែបរដ្ឋប្បវេណី បង្ហាញពីនិន្នាការនៃការបំភ័យតាមផ្លូវច្បាប់ ដែលមានគោលបំណងបំបិទសំឡេងការរាយការណ៍បែបរិះគន់។

នៅពេលយកបញ្ហាទាំងអស់មកពិចារណារួមគ្នា ការវិវឌ្ឍទាំងនេះបង្ហាញពីការកើនឡើងនៃការគ្រប់គ្រងរបស់រដ្ឋលើប្រព័ន្ធផ្សព្វផ្សាយនិងការកើនឡើងនៃបរិយាកាសភ័យខ្លាចដែលកំពុងប៉ះពាល់ដល់ការទទួលបានព័ត៌មានរបស់សាធារណជននិងគណនេយ្យភាពប្រជាធិបតេយ្យ។ ប្រសិនបើគ្មានកំណែទម្រង់បន្ទាន់ដើម្បីកែសម្រួលឬលុបចោលបទប្បញ្ញត្តិដែលមានលក្ខណៈរឹតត្បិត បញ្ឈប់ការប្រើប្រាស់នីតិវិធីច្បាប់មកប្រើប្រាស់មានលក្ខណមិនត្រឹមត្រូវ និងធានាការការពារក៏ដូចជាការទទួលខុសត្រូវចំពោះការរំលោភបំពានលើអ្នកសារព័ត៌មានទេ នោះលំហប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា នឹងកាន់តែបន្តរួមតូច។ ការណ៍នេះអាចនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរលើសេរីភាពបញ្ចេញមតិ និងអភិបាលកិច្ចប្រជាធិបតេយ្យ។ ការការពារអ្នកសារព័ត៌មាន មិនមែនជារឿងសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកសារព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែវាមានសារៈសំខាន់សម្រាប់ការការពារអភិបាលកិច្ចប្រជាធិបតេយ្យ តម្លាភាព និងសិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន។

ខេមបូចា នៅតែប្តេជ្ញាចិត្តបន្តកត់ត្រាបញ្ហាប្រឈមទាំងនេះ និងតស៊ូមតិដើម្បីបង្កើតបរិយាកាសប្រព័ន្ធផ្សព្វផ្សាយមួយនៅកម្ពុជាដែលគោរពយ៉ាងពេញលេញនូវការធានាទាំងឡាយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ដោយធានាថាអ្នកសារព័ត៌មានអាចបំពេញការងារបានដោយសេរី សុវត្ថិភាព និងគ្មានការភ័យខ្លាច។





# ៦. ឧបសម្ព័ន្ធ

### ១. ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ ខេត្តឧត្តរមានជ័យ

អ្នកសារព័ត៌មានចំនួន៦នាក់ មកពីស្ថាប័នផ្សព្វផ្សាយចំនួនពីរ ដែលក្នុងនោះមានអ្នកសារព័ត៌មានស្ត្រីម្នាក់ផង ត្រូវបាននគរបាលឃុំជើងទៀន ចាប់ខ្លួន ខណៈពេលកំពុងថតពីស្ពានមួយក្នុងស្រុកចុងកាល់ ខេត្តរមានជ័យ ដែលត្រូវបានរាយការណ៍ថារងការវាយប្រហារដោយគ្រាប់បែកពីកងទ័ពថៃ។ អ្នកសារព័ត៌មានម្នាក់បានប្រាប់ ខេមបូចា ថា លោក និងសហការី ត្រូវបាននាំទៅសាកសួរនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ប្រហែល២ម៉ោង នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥។ ហេតុការណ៍នេះកើតឡើងនៅពេលក្រុមអ្នកសារព័ត៌មានធ្វើដំណើរទៅឃុំជើងទៀន ដើម្បីរាយការណ៍អំពីទីតាំងមួយ ដែលត្រូវបានរាយការណ៍ថារងការវាយប្រហារដោយគ្រាប់បែកដែលទម្លាក់ដោយកងកម្លាំងយោធាថៃ។

តាមការរៀបរាប់របស់អ្នកសារព័ត៌មាន នគរបាលបានចូលមករកក្រុមអ្នកសារព័ត៌មាន ខណៈពេលពួកគេកំពុងថតរូបទីតាំងដែលរងការវាយប្រហារដោយគ្រាប់បែក និងជំរុជនភៀសខ្លួននៅក្បែរនោះ បន្ទាប់មកបាននាំពួកគេទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ។ លោកបានបញ្ជាក់ថា នគរបាលបានចោទថា អ្នកសារព័ត៌មានមិនមានលិខិតបេសកកម្មផ្លូវការ និងបានសង្ស័យថាពួកគេពាក់ព័ន្ធនឹងសកម្មភាពចារកម្ម។

អ្នកសារព័ត៌មានរូបនោះបានបន្ថែមថា នគរបាលបានយកទូរសព្ទដៃនិងម៉ាស៊ីនថតរបស់អ្នកសារព័ត៌មានទៅពិនិត្យបណ្តោះអាសន្ន ហើយតម្រូវឱ្យពួកគេសរសេរលិខិតបញ្ជាក់អត្តសញ្ញាណថាជាអ្នកសារព័ត៌មាន។ បន្ទាប់ពីការសាកសួរ អ្នកសារព័ត៌មានទាំង៦នាក់ត្រូវបានដោះលែងវិញ។

អ្នកសារព័ត៌មានស្ត្រីដែលក្នុងហេតុការណ៍នោះដែរបានប្រាប់ថាអាជ្ញាធរមិនបានជូនដំណឹងដល់ក្រុមរបស់គាត់ថាតំបន់នោះជាតំបន់ហាមឃាត់ឡើយ ដូច្នេះពួកគេបានទៅកាន់ទីតាំងនោះដើម្បីរាយការណ៍អំពីហេតុការណ៍ដែលបានកើតឡើងប៉ុណ្ណោះ។ អ្នកសារព័ត៌មានដដែលបានពន្យល់ថា ខណៈពេលក្រុមការងារកំពុងត្រៀមថតរូប និងថតវីដេអូនៅទីតាំងនោះស្រាប់តែមន្ត្រីនគរបាលក៏បានមកដល់ហើយស្រែកសួរថាហេតុអ្វីបានជាពួកគេថតរូបនិងពួកគេមកតំណាងឱ្យស្ថាប័នផ្សព្វផ្សាយមួយណា។ តាមការរៀបរាប់របស់អ្នកសារព័ត៌មាន នគរបាលបានឆែកឆេរយានជំនិះរបស់ពួកគេ ពិនិត្យរកឧបករណ៍ចាប់ទីតាំង(GPS) និងដកហូតទូរស័ព្ទរបស់ពួកគេ។ មន្ត្រីនគរបាលក៏បានស្នើសុំលិខិតបេសកកម្ម ហើយបន្ទាប់មកបាននាំអ្នកសារព័ត៌មានទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ដែលពួកគេត្រូវបានសាកសួររយៈពេលជាច្រើនម៉ោង។ តាមការរាយការណ៍ នគរបាលបានប្រាប់ថា តំបន់នោះត្រូវបានកំណត់ជាតំបន់ហាមឃាត់ ដោយសារការព្រួយបារម្ភអំពីសកម្មភាពចារកម្ម។

អ្នកសារព័ត៌មានស្ត្រីរូបនោះបានបន្តថាបន្ទាប់ពីពួកគេបានសរសេរលិខិតបញ្ជាក់លម្អិតពីអត្តសញ្ញាណ និងប្រវត្តិវិជ្ជាជីវៈរបស់ខ្លួន ពួកគេក៏ត្រូវបានដោះលែងវិញ។(ប្រភេទសកម្មភាព៖ ការឃាត់ខ្លួន)

## ២. ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ខេត្តឧត្តរមានជ័យ

អ្នកសារព័ត៌មានខ្មែរម្នាក់នៅខេត្តឧត្តរមានជ័យ បានរងរបួសដោយគ្រាប់ផ្លោងរបស់យោធាថៃ នាថ្ងៃទី៨ ខែធ្នូ ខណៈពេលកំពុងរាយការណ៍អំពីការប៉ះទង្គិចតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

លោក ប៉ុល ឆាំ ជាអ្នកសារព័ត៌មានអង្គភាពព័ត៌មានសេះស បានរងរបួសធ្ងន់នៅមាត់ បន្ទាប់ពីត្រូវអំបែងគ្រាប់ផ្លោង។ តាមការបញ្ជាក់របស់កូនស្រីលោក នៅពេលនោះលោកកំពុងថតវីដេអូអំពីការផ្ទុះគ្រាប់ ដែលត្រូវបានរាយការណ៍ថាបាញ់ចេញពីភាគីថៃ ចូលមកក្នុងទឹកដីកម្ពុជា នៅឃុំគោកមន ស្រុកបន្ទាយអំពិល។

កូនស្រីរបស់អ្នកសារព័ត៌មានរូបនេះបានប្រាប់ខេមបូចា បន្ថែមថាប្រហែលម៉ោង៦ព្រឹក ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ មានសំឡេងផ្ទុះឮនៅជិតភូមិរបស់ពួកគេ ហើយឪពុករបស់នាងបានចាកចេញពីផ្ទះភ្លាមៗ ដើម្បីទៅរាយការណ៍ព័ត៌មានអំពីហេតុការណ៍នេះ។ បន្តិចក្រោយមក គាត់បានព្យាយាមទូរស័ព្ទទៅឪពុក ប៉ុន្តែមិនមានការឆ្លើយតបឡើយ។ ពេលក្រោយមកគាត់បានទទួលដំណឹងថាឪពុករបស់ខ្លួនបានរងរបួសធ្ងន់ដោយសារអំបែងគ្រាប់ផ្លោងប៉ះចំមាត់។ គាត់ជឿថាហេតុការណ៍នេះកើតឡើងនៅចន្លោះម៉ោង៧ដល់ម៉ោង៨ព្រឹក។ លោក ឆាំ ត្រូវបានបញ្ជូនទៅព្យាបាលបន្ទាន់នៅមន្ទីរពេទ្យខេត្ត។ (ប្រភេទសកម្មភាព៖ ការរងរបួសដោយសារគ្រាប់ផ្លោង)

## ៣. ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ ខេត្តកំពត

នៅថ្ងៃទី៣០ ខែវិច្ឆិកា ចាងហ្វាងសារព័ត៌មាន Questioncam News ត្រូវបាននគរបាលខេត្តកំពតឃាត់ខ្លួនតាមអំពើចិត្ត បន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីភាពមិនប្រក្រតីដែលត្រូវបានចោទប្រកាន់ក្នុងការគ្រប់គ្រងផ្សារនៅមូលដ្ឋានមួយកន្លែង។

អ្នកសារព័ត៌មានរូបនោះបានប្រាប់ខេមបូចានៅថ្ងៃទី១ ខែធ្នូ ថាមន្ត្រីនគរបាលបានមកដល់ផ្ទះមិត្តភក្តិរបស់លោកដែលលោកកំពុងស្នាក់នៅ ហើយនាំលោកទៅកាន់ស្នងការដ្ឋាននគរបាលខេត្ត ដើម្បីសាកសួរ។ លោកបានបដិសេធមិនបង្ហាញព័ត៌មានលម្អិតអំពីសំណួរដែលបានសួរក្នុងអំឡុងពេលសាកសួរនោះទេ។

នៅពេលត្រូវសួរថា តើសេចក្តីរាយការណ៍ណាអាចជាមូលហេតុឈានទៅដល់ការឃាត់ខ្លួននេះឬយ៉ាងណា អ្នកសារព័ត៌មានរូបនេះបានឆ្លើយថា លោកមិនប្រាកដទេ ដោយពន្យល់ថា លោកបានផ្សព្វផ្សាយព័ត៌មានជាច្រើនដែលលាតត្រដាងអំពីភាពអសកម្ម និងភាពមិនប្រក្រតីនៅខេត្តកំពត។ ទោះយ៉ាងណា លោកជឿថា ការឃាត់ខ្លួនអាចពាក់ព័ន្ធនឹងការផ្សាយផ្ទាល់មួយដែលលោកបានធ្វើនៅថ្ងៃទី២៩ ខែវិច្ឆិកា នៅផ្សារសាមគ្គី ដែលរាយការណ៍អំពីភាពមិនប្រក្រតីក្នុងការគ្រប់គ្រងផ្សារ។

មុនពេលមានការឃាត់ខ្លួន មានការបង្ហោះលើទំព័រ Facebook របស់ Questioncam News ដែលសរសេរថា «នគរបាលមួយក្រុមបានឃាត់ខ្លួនខ្ញុំ ហើយបង្ខំឱ្យខ្ញុំទៅក្រុងកំពត បន្ទាប់ពីខ្ញុំបានរាយការណ៍អំពីភាពមិនប្រក្រតីនៅផ្សារសាមគ្គី»។ ការបង្ហោះនោះត្រូវបានលុបចេញវិញនៅពេលក្រោយ។





នៅល្ងាចថ្ងៃដដែលនាម៉ោង៧:៤០នាទី អ្នកសារព័ត៌មានរូបនោះបានបង្ហោះវីដេអូសុំទោស ផ្ញើជូនអាជ្ញាធរខេត្តកំពត ដោយទទួលស្គាល់ថា ការរាយការណ៍មុនរបស់លោកមានព័ត៌មានមិនទាន់គ្រប់ជ្រុងជ្រោយ ហើយសន្យាថានឹងមានការប្រុងប្រយ័ត្នជាងនេះនៅពេលរាយការណ៍ព័ត៌មានលើកក្រោយ។

លោកបានប្រាប់ខេមបូចាថា លោកជឿថាការរាយការណ៍របស់លោកមិនមានអ្វីខុសទេ។ ទោះយ៉ាងណា ដើម្បីការពារស្ថាប័នផ្សព្វផ្សាយរបស់លោក លោកបានយល់ព្រមធ្វើវីដេអូសុំទោស ដើម្បីប្តូរជាមួយការដោះលែង។ តាមការរៀបរាប់របស់លោក វីដេអូសុំទោសនោះត្រូវបានថតនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ។ លោកត្រូវបានដោះលែងនៅម៉ោង៨:១៦នាទីយប់ ថ្ងៃដដែល។ (ប្រភេទសកម្មភាព៖ ការឃាត់ខ្លួន)

## ៤. ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៥ ខេត្តមណ្ឌលគិរី

អ្នកសារព័ត៌មានស្ត្រីម្នាក់នៅខេត្តមណ្ឌលគិរី បាននិយាយថាគាត់បានប្រឈមនឹងការបំភ័យពីបុគ្គលមិនស្គាល់អត្តសញ្ញាណបន្ទាប់ពីបានរាយការណ៍ជាបន្តបន្ទាប់អំពីសកម្មភាពរ៉ែខុសច្បាប់ដែលសង្ស័យថាកំពុងកើតមាននៅភូមិពូទង់ឃុំចុងផ្លាសស្រុកកែវសីមា។

នៅក្នុងខែវិច្ឆិកាគាត់បានផ្សព្វផ្សាយអត្ថបទចំនួនពីរដែលចេញផ្សាយ នៅថ្ងៃទី១២ និងថ្ងៃទី១៥ ដែលបានរាយការណ៍ពីសកម្មភាពដែលអ្នកសារព័ត៌មានរូបនេះបានពណ៌នាថាជាការធ្វើអាជីវកម្មរ៉ែខុសច្បាប់ក្នុងតំបន់នោះ។

គាត់បានប្រាប់ ខេមបូចា នៅថ្ងៃទី១៨ ខែវិច្ឆិកា ថា ប្រហែលម៉ោង២រំលងអធ្រាត្រ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៥ មានបុគ្គលមិនស្គាល់អត្តសញ្ញាណយ៉ាងហោចណាស់ពីរនាក់ បានគប់ដុំថ្មចូលផ្ទះរបស់គាត់ បណ្តាលឱ្យទូកញ្ចក់មួយបែក និងបំផ្លាញទ្រព្យសម្បត្តិផ្សេងទៀតរបស់គាត់ផងដែរ។

ហេតុការណ៍នេះបានកើតឡើងនៅភូមិដែលគាត់ទើបតែបានចុះរាយការណ៍ព័ត៌មានពីសកម្មភាពរុករករ៉ែនោះ។ អ្នកសារព័ត៌មានរូបនេះបានបញ្ជាក់ថា គាត់មិនមានជម្លោះផ្ទាល់ខ្លួនជាមួយនរណាម្នាក់ឡើយ។ ទោះយ៉ាងណាមួយថ្ងៃមុនហេតុការណ៍កើតឡើង គឺនៅថ្ងៃទី១៥ ខែវិច្ឆិកា គាត់បានថតវីដេអូអំពីសកម្មភាពជីកកកាយដែលកំពុងបន្តកើតមានប្រព្រឹត្តដោយមនុស្សមួយក្រុមនៅក្នុងឃុំចុងផ្លាស់។ គាត់ក៏បានកត់សម្គាល់ថា ទីតាំងនោះធ្លាប់គ្រប់គ្រងដោយក្រុមហ៊ុនចិនមួយ។

គាត់សង្ស័យថា អ្នកប្រព្រឹត្តអាចពាក់ព័ន្ធនឹងសកម្មភាពជីករករ៉ែ ដោយបញ្ជាក់ថា គាត់បានឃើញមុខបុគ្គលម្នាក់ក្នុងរយៈពេលខ្លីអំឡុងពេលហេតុការណ៍វាយប្រហារនេះ ប៉ុន្តែមិនច្បាស់គ្រប់គ្រាន់ដើម្បីកំណត់អត្តសញ្ញាណបានទេ។

នៅព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា គាត់បានដាក់ពាក្យបណ្តឹងទៅនគរបាលឃុំចុងផ្លាស់ និងស្នើសុំមើលកាមេរ៉ាសុវត្ថិភាព (CCTV) របស់អ្នកជិតខាង។ ក្រោយមក នគរបាលបានប្រាប់គាត់ថា កាមេរ៉ានោះមិនដំណើរទេការនៅពេលកើតហេតុនោះ។ បច្ចុប្បន្ន គាត់នៅតែរង់ចាំចំណាត់ការបន្តរបស់អាជ្ញាធរពាក់ព័ន្ធនឹងសំណុំរឿងរបស់ខ្លួន។

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ មេប៉ុស្តិ៍រដ្ឋបាលនគរបាលឃុំចុងផ្លាស់ លោក ចាន់ សុភារី បានប្រាប់ ខេមបូចា ថា លោកបានទទួលពាក្យបណ្តឹងពីអ្នកសារព័ត៌មានរូបនេះ ហើយនគរបាលកំពុងដំណើរការស្រាវជ្រាវករណីនេះ។ (ប្រភេទសកម្មភាពៈ អំពើហិង្សាផ្នែករាងកាយ)

## ៥. ថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២៥ ខេត្តកណ្តាល

ចាងហ្វាងសារព័ត៌មាន AK News បានទទួលរងអំពើហិង្សាលើរាងកាយ និងត្រូវបានហាមឃាត់មិនឱ្យរាយការណ៍ព័ត៌មាន ដោយអភិបាលរងខេត្តកណ្តាល ខណៈពេលកំពុងផ្សាយបន្តផ្ទាល់អំពីការតវ៉ាជាសាធារណៈមួយ។

យោងតាមវីដេអូដែលបានចែករំលែកលើហ្វេសប៊ុក ហេតុការណ៍នេះបានកើតឡើងនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ក្នុងអំឡុងការតវ៉ាមួយ ដែលប្រជាពលរដ្ឋទាមទារឱ្យឧកញ៉ា ឡេង ណាវ៉ាត្រា បំពេញសន្យាផ្តល់ផ្ទះជូនអតិថិជន។ វីដេអូនោះបង្ហាញថា អភិបាលរងខេត្តបានរុញអ្នកសារព័ត៌មានទៅម្ខាង ខណៈដែលគាត់ព្យាយាមសម្ភាសន៍មន្ត្រីរូបនោះ។

អ្នកសារព័ត៌មានរូបនេះបានឱ្យខេមបូចាដឹងថា គាត់បានទៅកន្លែងតវ៉ា បន្ទាប់ពីទទួលព័ត៌មានពីប្រជាពលរដ្ឋដែលកំពុងបិទផ្លូវជាតិលេខ៦A ដើម្បីទាមទារការប្រគល់ផ្ទះតាមសន្យា។ នៅពេលគាត់ទៅដល់ អាជ្ញាធរខេត្តបានស្ថិតនៅទីនោះរួចហើយ ដើម្បីសម្រួលស្ថានការណ៍។ គាត់បានព្យាយាមសម្ភាសន៍អភិបាលរងខេត្តពីដំណោះស្រាយដែលអាចមាន ប៉ុន្តែមន្ត្រីនោះបដិសេធមិនឆ្លើយតប ហើយថែមទាំងបានរុញស្មារបស់គាត់ទៀតផង។ លោកបានបង្ហាញការខកចិត្តចំពោះហេតុការណ៍នេះ ដោយនិយាយថាទោះបីគាត់ខិតខំរាយការណ៍ដើម្បីផលប្រយោជន៍សាធារណៈយ៉ាងណាក្តី ក៏លោកត្រូវបានអាជ្ញាធរប្រព្រឹត្តដាក់មិនសមរម្យដែរ។ (ប្រភេទសកម្មភាពៈ ហិង្សាលើរាងកាយ)

## ៦. ថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០២៥ ខេត្តបន្ទាយមានជ័យ

នៅថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០២៥ សាលាដំបូងខេត្តបន្ទាយមានជ័យ បានសួរចម្លើយលោក អ៊ុង ចាប់ រាំង ចាងហ្វាងសារព័ត៌មានខ្មែរជាយដែន ជាលើកទីពីរ ហើយសម្រេចដាក់លោកស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ពាក់ព័ន្ធនឹងបណ្តឹងដែលដាក់ដោយនគរបាលក្រុងប៉ោយប៉ែត កាលពីខែមិថុនា។

នៅថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០២៥ លោក ចាប់រាំង ត្រូវបានឃាត់ខ្លួនមួយយប់ ដើម្បីសួរចម្លើយដោយនគរបាលខេត្ត និងមន្ត្រីតុលាការ។ ក្រោយមក លោកត្រូវបានដោះលែង បន្ទាប់ពីតុលាការរកឃើញថាមិនមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចោទប្រកាន់។ អង្គការសិទ្ធិមនុស្សលីកាដូបានរាយការណ៍ថា តុលាការបានបង្គាប់ឱ្យលោក ចាប់រាំង គោរពតាមលក្ខខណ្ឌតឹងរឹងក្រោមមាត្រា ២២៣ នៃក្រមព្រហ្មទណ្ឌ។

លោក ចាប់រាំង បានប្រាប់ខេមបូចានៅថ្ងៃទី២៣ ខែតុលា ថាលោកត្រូវបានបង្គាប់ឱ្យបង្ហាញខ្លួននៅតុលាការរៀងរាល់ពីរសប្តាហ៍ម្តង រហូតដល់ការជំនុំជម្រះចាប់ផ្តើម។ លោកបានពិពណ៌នាចំណាត់ការរបស់តុលាការថាជា «ការសងសឹក» ពីអាជ្ញាធរមូលដ្ឋាន បន្ទាប់ពីលោកបានដាក់ពាក្យបណ្តឹងទៅក្រសួងមហាផ្ទៃ ចោទប្រកាន់ពីការឃាត់ខ្លួនលោក ក្នុងអំឡុងពេលសួរចម្លើយកាលពីខែមិថុនា។ លោកបានបន្ថែមថា លោកក៏បានស្នើសុំអន្តរាគមន៍ពីក្រសួងព័ត៌មានផងដែរ។





បណ្តឹងប្រឆាំងនឹងលោក ចាប់រាំង ពាក់ព័ន្ធនឹងអត្ថបទដែលលោកបានចេញផ្សាយនៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២៥ អំពីអធិការនៃអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែតលោក ព្រហ្ម ពិសិដ្ឋ ។ អត្ថបទនោះរាយការណ៍អំពីបុរសម្នាក់ដែលត្រូវបានវាយប្រហារយ៉ាងធ្ងន់ធ្ងរ ហើយក្រោយមកបានដាក់ពាក្យបណ្តឹងទៅក្រសួងមហាផ្ទៃ ដោយចោទប្រកាន់ថាអធិការនគរបាលរូបនេះបានបង្ហាញព័ត៌មានមិនត្រឹមត្រូវអំពីករណីរបស់ខ្លួន។ តាមការបញ្ជាក់របស់លោក ចាប់រាំង ព័ត៌មាននេះគឺជាមូលដ្ឋានដែលប្រើសម្រាប់បណ្តឹងប្រឆាំងនឹងរូបលោក។

នេះមិនមែនជាលើកទីមួយទេដែលចាងហ្វាងសារព័ត៌មានខ្មែរជាយដែនរូបនេះប្រឈមមុខនឹងវិធានការផ្លូវច្បាប់។ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣ លោកត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ ពាក់ព័ន្ធបទញុះញង់ បន្ទាប់ពីការរាយការណ៍អំពីអំពើពុករលួយដែលសង្ស័យថាកើតមានក្នុងមន្ទីរពេទ្យបង្អែក និងពន្ធដារក្រុងប៉ោយប៉ែត។ លោកត្រូវបានដោះលែងវិញនៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០២៣។

នៅខែមករា ឆ្នាំ ២០២៤ លោក ចាប់រាំង ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ៦ ខែ ដោយទោសត្រូវព្យួរ និងទទួលរងការពិន័យជាប្រាក់២លានរៀល។ នៅខែមករា ឆ្នាំ២០២៥ តុលាការកំពូលបានតម្កល់ទុកសាលក្រមផ្តន្ទាទោស ប៉ុន្តែលុបចោលការផាកពិន័យ។ (ប្រភេទសកម្មភាពៈ ការយាយីតាមផ្លូវច្បាប់)

## ៧. ថ្ងៃទី ១ ខែតុលា ឆ្នាំ ២០២៥ រាជធានីភ្នំពេញ

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ អ្នកសារព័ត៌មានវិទ្យុក្នុងស្រុកម្នាក់ត្រូវបានហាមឃាត់មិនឱ្យរាយការណ៍អំពីការកើនឡើងកម្ពស់ទឹកទន្លេមេគង្គ នៅរាជធានីភ្នំពេញ។

អ្នកសារព័ត៌មានរូបនោះបានប្រាប់ខេមបូចាថា នៅថ្ងៃកើតហេតុប្រហែលម៉ោង១១ព្រឹក លោកកំពុងថតវីដេអូ និងថតរូបពីកម្រិតទឹកទន្លេដែលកំពុងឡើងខ្ពស់ដែលបានលិចចិញ្ចើមផ្លូវ និងតំបន់អាជីវកម្មក្បែរៗក្នុងតំបន់អភិវឌ្ឍន៍ក្រុងរណបកោះនរា។ លោកបាននិយាយថា ខណៈពេលលោកនិងក្រុមការងារកំពុងថតទិដ្ឋភាពនោះ ក្រុមសន្តិសុខបានចូលមកសួរអំពីគោលបំណងនៃការថតនោះ។

បន្ទាប់ពីដឹងថាលោកជាអ្នកសារព័ត៌មាន ក្រុមសន្តិសុខបានបញ្ជាឱ្យលោកបញ្ឈប់សកម្មភាពថតភ្លាម។ ទោះជាយ៉ាងណា លោកនៅតែបន្តការងារ ដែលបណ្តាលឱ្យសន្តិសុខព្រមានថា «នឹងមានបញ្ហា» ប្រសិនបើលោកមិនឈប់នោះទេ។ ក្រុមសន្តិសុខក៏បានប្រាប់ថាអ្នកសារព័ត៌មានត្រូវសុំការអនុញ្ញាតជាមុន មុនពេលថតវីដេអូ ឬថតរូប។ អ្នកសារព័ត៌មានបានបដិសេធការទាមទារនេះ ដោយបញ្ជាក់ថា លោកកំពុងថតពីទីតាំងសាធារណៈ។ (ប្រភេទសកម្មភាពៈ ការរារាំងមិនឱ្យចូលយកព័ត៌មាន)

**រាយការណ៍អំពីករណីរំលោភសិទ្ធិមនុស្សលើអ្នកសារព័ត៌មាន ៖**

+៨៥៥ ១០ ៨៨២ ៣១១ (តេឡេក្រាម)

feedback@camboja.net

អេសអេសភី អូហ្វីស ស្ពេស ជាន់ទី៤(G) ផ្ទះលេខ៤៨
មហាវិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់២
ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា

www.camboja.net